ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២១

នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្មតាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់៖

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអាស៊ានស្តីពី ការពង្រឹងយន្តការដោះស្រាយវិវាទ

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ប្រជុំបើកទូលាយជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រមទាំងចាត់ចែងតាមនីតិវិធី

- បានទទួលព្រះរាជក្រឹត្យ សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៣៦ច្បាប់

-បានសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានធ្វើកំណត់បង្ហាញអនុក្រឹត្យ របាយការណ៍ សេចក្តីជូនដំណឹង ប្រកាស និងលិខិត

ផ្សេងៗចំនួន៣៤ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន១៨លើក។

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា អញ្ជើញជួបសវនាការ និងពិភាក្សាការងារ ជាមួយរដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍, តំណាងក្រសួងយុត្តិធម៌, តំណាងគណៈកម្មការសិទ្ធិមនុស្សកម្ពុជា និងគណៈកម្មការទី១រដ្ឋសភា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារគ្នាទៅវិញទៅមក និងឈ្វេងយល់អំពីវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចូលរួមប្រជុំឈ្វេងយល់អំពីប្រវត្តិសាស្ត្រសង្ខេបនៃកម្ពុជា សីលធម៌សង្គម និងបដិវត្តន៍ឧស្សាហកម្មក្នុងគោលបំណងសំដៅវាយតម្លៃឱ្យបានត្រឹមត្រូវបញ្ហាពាក់ព័ន្ធនឹងសីលធម៌សង្គម ការរក្សាអត្តសញ្ញាណជាតិ វប្បធម៌ជាតិ ការអប់រំប្រវត្តិសាស្ត្រជាតិ និងការអប់រំផ្នែកវិទ្យាសាស្ត្របច្ចេកទេសដែលជាកម្លាំងចលករក្នុងការអភិវឌ្ឍប្រទេសជាតិ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរឯកឧត្តមលេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់អំពីការផ្សព្វផ្សាយច្បាប់ស្តីពី វិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញនៅខេត្តត្បូងឃ្មុំ។

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី** អញ្ជើញជាគណៈអធិបតីក្នុងពិធីពន្លត់ទៀនជ័យ បុណ្យខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា នៅវិមានឯករាជ្យ

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចូលរួមដង្ហែ និងទទួលព្រះរាជដំណើរ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ស្តេចយាងនិវត្តន៍ពីការចូលរួមពិធីបើកសម័យប្រជុំមហាសន្និបាតលើកទី៤១ ក្នុងឱកាសបុណ្យខួបលើកទី៧៥ នៃអង្គការយូណេស្កូ នៅសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំខេត្ត មន្ត្រី និងអាជ្ញាធរមូលដ្ឋានក្នុងខេត្តកំពង់ធំ ខេត្តកំពត និងខេត្តព្រះសីហនុ ព្រមទាំងចុះពិនិត្យអាងប្រព្រឹត្តកម្មទឹកកខ្វក់ទី២(PS2) ដែលមានសមត្ថភាពសម្អាតទឹកកខ្វក់បានចំនួន៧,២០០ម៉ែត្រគូបក្នុងមួយថ្ងៃ ជិតសណ្ឋាគារសុខា សង្កាត់លេខ៣ ក្រុងកំពង់សោម, ពិនិត្យបន្ទប់ទឹកសាធារណៈផ្លូវទាំង៣៤ខ្សែ ក្នុងខេត្តព្រះសីហនុ

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និងពិធីពន្លត់ទៀនជ័យនៃទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី** ព្រមទាំងអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមពិធីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ និងបញ្ចុះសពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ងួន ញ៉ិល** អនុប្រធានទី១នៃរដ្ឋសភា នៅខេត្តកំពង់ធំ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបពិភាក្សាការងារជូន**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** ជាមួយលោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋានដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសចុះឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ការដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល អប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាប្រក្រតីក្នុងបរិបទនៃជំងឺកូវីដ-១៩ ការងារចាក់វ៉ាក់សាំងបង្ការជូនប្រជាពលរដ្ឋ ព្រមទាំងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗចំនួន៩៩លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តកោះកុង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

- បាននាំយកកម្រងផ្កា និងបច្ច័យរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពលោកជំទាវ **ស៊ី តួន** ចៅសង្កាត់ផ្សារថ្មី១ ដែលបានទទួលមរណភាព

- បានទទួលពាក្យបណ្តឹងចំនួន០៨ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០៧ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៧ករណី និងកំពុងពិនិត្យសិក្សាចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៧ករណី និងទទួលលិខិតឆ្លើយតបពីការ

ដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០២ករណី

- បានធ្វើបទបង្ហាញស្តីពី តួនាទី ភារកិច្ច របស់ព្រឹទ្ធសភា ជូនសិក្ខាកាមមកពីសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប តាមប្រព័ន្ធវីដេអូ

- បានផ្ញើសារលិខិតថ្វាយព្រះពរ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងព្រះរាជពិធីគម្រប់១៧ព្រះវស្សា នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ និងជូនពរ**សម្តេចចៅហ្វាវាំង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង,** សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី ក្នុងឱកាសចម្រើនជន្មាយុ

- បានផ្ញើសាររំលែកទុក្ខជូនមន្ត្រីជាន់ខ្ពស់ និងឥស្សរជននានាចំនួន០៦លើក

- បានផលិតទស្សនាវដ្តីប្រចាំខែវិច្ឆិកា ឆ្នាំ២០២១ ចំនួន៨០០ក្បាល។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសវនាការ និងសម្តែងការគួរសមជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តមបណ្ឌិត **ផនខាំ វីផាវ៉ាន់** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងឯកឧត្តម **ង្វៀន ហ៊ុយតាំង** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា, តំណាងក្រុមហ៊ុនជីហ្គូគ្លូបល់(G.go Globa), តំណាងក្រុមហ៊ុនស៊ីភី (CP) ផ្នែកចិញ្ចឹមសត្វលើគោក និងក្នុងទឹក និងលោកស្រី **ចាន់ ភារី** នាយិកាក្រុមហ៊ុនគីណូ ឃែរ ខនស៊ូមមី (ខេមបូឌៀ)

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំនានារួមមានៈ កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១១ (ASEP11) ដែលសភាកម្ពុជាធ្វើជាម្ចាស់ផ្ទះ ក្រោមមូលបទ "ការលើកកម្ពស់ភាពជាដៃគូសភា ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាពទាំងក្នុងសម័យ និងក្រោយវិបត្តិកូវីដ-១៩" ក្រោមអធិបតីភាព**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** និងជាសហប្រធាន (ASEP11), មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកសភាប្រើភាសាបារាំង, កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១(ASEAN11) តាមប្រព័ន្ធវីដេអូ, មហាសន្និបាតសហភាពអន្តរសភាលើកទី១៤៣ (IPU-143)

និងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) នៅប្រទេសអេស្ប៉ាញ, កិច្ចប្រជុំ ASEAN+3 និងASIA-PACIFIC ក្នុងក្របខណ្ឌ IPU លើកទី១៤៣ នៅវិមានព្រឹទ្ធសភា និងចូលរួមសន្និបាតបូកសរុបការងារក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិឆ្នាំ២០២១ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យកម្មសិក្សាការីជនជាតិបារាំង ចូលជួបសម្តែងការគួរសម និងជម្រាបលា

- បានរៀបចំចាត់ចែងជូនអគ្គលេខាធិការរងព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយសៀវភៅសិក្សាស្រាវជ្រាវគាំទ្រកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ កិច្ចសហប្រតិបត្តិការពហុភាគីនិយម ដើម្បីអនាគតដែលមានភាពធន់ ចីរភាព និងផ្អែកលើច្បាប់សម្រាប់ASEM តាមប្រព័ន្ធវីដេអូ

- បានរៀបចំចាត់ចែងជូនមន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមសន្និសីទប្រចាំឆ្នាំលើកទី២៣ របស់វិទ្យាស្ថាន (KPI) ក្រោមប្រធានបទស្តីពី លទ្ធិប្រជាធិបតេយ្យក្នុងទិដ្ឋភាពថ្មី តាមប្រព័ន្ធវីដេអូ

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា, ស្ថានទូតចិន, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, វិទ្យាស្ថានសភាអាស៊ី(PCA), វិទ្យាស្ថានសាន់ហ៉ាយស៍, វិទ្យាស្ថានជាតិស្ថិតិ(NIS), ក្រុមហ៊ុនCambodia Hosting, ក្រុមហ៊ុនKOHA និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បានប្រជុំពិនិត្យសេចក្តីព្រាងសេចក្តីសម្រេចគោលការណ៍ដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរដោយគ្មានបៀវត្ស

- បានប្រជុំការងារបេឡាសន្តិសុខសង្គម

- បានប្រជុំគណៈកម្មការក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើករណីមន្ត្រីរាជការនៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ

- បានប្រជុំត្រួតពិនិត្យការងារសំខាន់ៗចំពោះមុខ និងកំណត់ទិសដៅការងារនាពេលខាងមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី។

## ៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានរៀបចំតារាងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានវិជ្ជមានកូវីដ-១៩ (កំពុងព្យាបាល និងជាសះស្បើយ)ចំនួន១០នាក់

- បានទទួលលិខិតចូលចំនួន៨៥៥ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៦៥ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានបើកប្រាក់បៀវត្សប្រចាំខែវិច្ឆិកា ឆ្នាំ២០២១ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែវិច្ឆិកា ឆ្នាំ២០២១

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន១០ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន ១០ប័ណ្ណ

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៧វគ្គ មានសិក្ខាកាមចូលរួមចំនួន១៤៤នាក់

- បានជូនដំណឹងផ្សព្វផ្សាយអាហារូបករណ៍ ក្រោមការគាំទ្ររបស់ការិយាល័យកុងស៊ុល សេដ្ឋកិច្ច និងពាណិជ្ជកម្មនៃស្ថានទូតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា សិក្សានៅសាធា-រណរដ្ឋប្រជាមានិតចិន

- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៣នាក់ ចូលរួមប្រឡង អាហារូបករណ៍ទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន នៅស្ថានទូតចិន ប្រចាំព្រះរាជាណា-ចក្រកម្ពុជា

- បានសង់រោងដែកសម្រាប់ដាក់ម៉ាស៊ីនភ្លើង និងកន្លែងដាក់ធុងសំរាម នៅខាងក្រោយ អគារជប៉ុន

- បានជួសជុលពង្រីកបន្ទប់នៅខាងក្រោយអគារសាលបណ្ណាល័យព្រឹទ្ធសភា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានា ព្រមទាំងដាំផ្កានៅខាងមុខអគារ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០ប្លង់

- បានចាត់ចែងកម្លាំងបាញ់ទឹកលាងផ្លូវ (P2) ចំនួន០២លើក និងកាប់ដើមស្វាយដួលរលំ នៅច្រកចូល (P1)

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា

និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៣០គ្រឿង/លើក

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

### ៥.២-ការងារស្រាវជ្រាវ៖

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងសិក្សាស្រាវជ្រាវការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៤៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែវិច្ឆិកា ឆ្នាំ២០២១ ចំនួន០៤ច្បាប់។

### ៥.៣-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៦២គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៧៥ប្រធានបទ

- បានបន្តចាត់ចែងការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅតាមជំនាញផ្សេងៗចំនួន៣៥ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ ដាក់លេខកូដសៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន៣៥ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៤២លើក

និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៨លើក

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្ដាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន។

**៥.៤-ការងារពិធីការៈ**

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣១លើក

- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៤ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែវិច្ឆិកា ឆ្នាំ២០២១ ចំនួន០១ច្បាប់។

**II-លទ្ធផលការងារគាំទ្រលើមុខងារនាំង៥ៈ**

- បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៥ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ ចងបដា និងពាក្យស្លោកចំនួន ១០លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន១១ច្បាប់ ស្មើនឹង៤៣នាក់

- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣៦៣លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន៥៣សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៤០លើក មានអ្នកចូលរួមចំនួន៥៣៧នាក់

- បានសួរសុខទុក្ខថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានជំងឺ

និងគ្រោះថ្នាក់ចរាចរណ៍ចំនួន០២នាក់

- បានប្រគល់ថវិកា និងទឹកអាល់កុលលាងដៃសម្លាប់មេរោគជូននិវត្តជន និងមន្ត្រីរ៉ាយចំណាស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២៧០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន២,៥៥១ច្បាប់ អស់ក្រដាសចំនួន៣៤,៧៣១សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១១៣លើក ស្មើនឹង២៥៥នាក់។ បានជួសជុល ប្តូរប្រេងម៉ាស៊ីន និងអាគុយរថយន្តចំនួន ០៧គ្រឿង

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន០៨លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន២,១៦០លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៧លើក។

**III-ទិសដៅការងារខែធ្នូ ឆ្នាំ២០២១**

***-បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឹតត្បិតឡុកដោន) ប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងពេលវេលាថ្មីដែលចាប់បើកប្រទេសឡើងវិញ និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖***

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមលក្ខណៈនៃការវិលត្រលប់មកកាន់ភាពប្រក្រតីនៃការអនុវត្តមុខងារស្នូលទាំង៣៖ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និង

ពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារៗ វត្តមានមន្ត្រី បុគ្គលិកត្រូវឈរលើគោលការណ៍សមមូលនៃទំហំការងារដើម្បីៈ**

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

-បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

-ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៧ និងទី៨ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាៈ

+ជួបពិភាក្សាការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា (ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១)។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចូលរួមពិធីបុណ្យជាតិសំខាន់ៗ

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទង

ជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា៖

+ត្រៀមពិធីសម្ពោធសមិទ្ធផលវត្តព្រែកព្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិ៍វង្ស នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា ការងារពិធីការជាតិ និងស្ថាប័ន កម្មវិធីជំនួប កម្មវិធីផ្លូវការ និងសាសនា ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU)ជាមួយរាជបណ្ឌិត្យ-សភាកម្ពុជា ឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស វិទ្យាស្ថានសភា-អាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU)ឡើងវិញជាមួយដៃគូសំខាន់ៗរបស់វិទ្យាស្ថានសភាអាស៊ី(PCA)ជាមួយរដ្ឋសភា-ព្រឹទ្ធសភាបារាំង លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)។ តាមដានការអនុវត្តជំនួយចិនសម្រាប់បណ្ណាល័យអេឡិចត្រូនិច និងគម្រោងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្តុះបណ្តាលជាបន្តបន្ទាប់

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA...)។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

-ការបញ្ចប់ផែនការការងារដំណាច់ឆ្នាំ បូកសរុប និងលើកទិសដៅឆ្នាំថ្មី

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-រយៈពេលបង្កើនការរឹតខ្សែក្រវ៉ាត់ដោយវិធានការវិចារណកម្មថវិកាក្នុងឆមាសទី២ និងត្បិតត្បៀតការចំណាយនៅចុងឆ្នាំ២០២១, ការកសាងថវិកាឆ្នាំថ្មី២០២២ ដោយគិតដល់តម្រូវការក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ ក្នុងឆមាសទី១ ឆ្នាំ២០២២៖ សម្ពាធនៃតម្រូវការអនុវត្តភាពតំណាងរបស់ព្រឹទ្ធសភា អនុវត្តស្វែងរកជំនួយចិន និងដៃគូ ដើម្បីចាប់ផ្តើមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ន

-ការត្រៀមរៀបចំជួសជុល កែលម្អអគារអតីតនាយកដ្ឋានព័ត៌មានវិទ្យា(ICT) ក្រោមអគារក្រហម

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែធ្នូចុងឆ្នាំ ឱ្យបានទាន់ពេលវេលា និងត្រៀមការងារថវិកា ខែមករា ឆ្នាំ២០២២ ឱ្យបានលឿន

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្តោតលើការងារជាអាទិភាព សំខាន់ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ធៀតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-អនុវត្តការងារ១ខែចុងឆ្នាំ តាមបរិបទកូវីដ-១៩ ដោយសម្រេចឱ្យបាននូវការងារជាអាទិភាព កសាងថវិកាឆ្នាំ២០២២ លើកផែនការ និងកម្មវិធីការងាររបស់ស្ថាប័ន និងគ្រប់អង្គភាពឆ្នាំ២០២២។ ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងការទូទាត់ថវិកាប្រចាំឆ្នាំ ត្រូវអនុវត្តទាន់ពេលវេលា ដោយស្មារតីទទួលខុសត្រូវ៖

+របាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងវិភាជន៍គម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ដើម្បីផ្តល់យោបល់សម្រេចក្នុងរចនាសម្ព័ន្ធរដ្ឋបាល និងនយោបាយ

+ការបោះពុម្ពទិនានុលេខន៍ ប្រតិទិន ប័ណ្ណរថយន្ត ត្រូវធានាគុណភាព និងបរិមាណសមស្របកម្មវិធីបុណ្យ និងកម្មវិធីផ្សេងៗទៀតត្រូវធានាការអនុវត្តឱ្យបានទាន់ពេលវេលា

-ធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈមៈ គោលការណ៍តមជ្រើសរើសថ្មីរហូតឆ្នាំ២០៣០ ការតម្លើងកាំប្រាក់ មុខតំណែង សន្ទស្សន៍បៀវត្សត្រូវរក្សាស្ថានភាពដដែលរហូតមានការណែនាំថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មីវិធីសាស្រ្តថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន គម្រោងជំនួយចិនក្នុងការសាងសង់ និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានាៗលៗ)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-បន្តការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន

-ត្រៀមធ្វើបឋកថាស្តីពីព្រឹទ្ធសភា និងទស្សនកិច្ចសិក្សា ជូនសិក្ខាកាមមន្ត្រីអាជ្ញាធរគ្រឿងញៀនចំនួន១១២នាក់ នៅសាលបណ្ណាល័យព្រឹទ្ធសភា

-ត្រៀមទទួលដំណើរទស្សនកិច្ចសិក្សារបស់និស្សិត និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ខេត្តបាត់ដំបងចំនួន១៩នាក់ នៅសាលសិក្ខាសាលាខាងជើង។

**IV-សេចក្តីសន្និដ្ឋាន**

ក្នុងខែវិច្ឆិកានេះ រាជរដ្ឋាភិបាលបានបើកដំណើរការសេដ្ឋកិច្ច និងសង្គម ជាជំហានៗឡើងវិញ តាមគន្លងប្រក្រតីភាពថ្មី ដោយរៀនរស់ជាមួយកូវីដ-១៩។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បន្តបោះជំហានទៅមុខយ៉ាងស្វាហាប់ ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការ អចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក បានយ៉ាងល្អប្រសើរ។ ជាពិសេសបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្តល់សេវាជូនគណៈកម្មការជំនាញទាំង១០ ចុះបំពេញបេសកកម្ម ជួបសន្ទនាការការងារជាមួយក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភា ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ការដោះស្រាយទុក្ខលំបាករបស់ ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេស អប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាប្រក្រតីក្នុងបរិបទនៃជំងឺកូវីដ-១៩ ការងារចាក់វ៉ាក់សាំងបង្ការ ជូនប្រជាពលរដ្ឋ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋ ដែលកំពុងជួបការលំបាក ព្រមទាំងប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និង ចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយ គណៈប្រតិភូជាតិ និងអន្តរជាតិ ព្រមទាំងកិច្ចប្រជុំនានាប្រព្រឹត្តទៅដោយរលូន។

មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាល នៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបាន ម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃអង្គារ [illegible] មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១

**អគ្គលេខាធិការ**

**អ៊ុំ_សារិទ្ធ**